គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតនៅឃុំសេដា ស្រុកលំផាត់ ខេត្តរតនៈគិរី

ដោយមានការគាំទ្រពី គណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង **សមាគមអាដហុក** បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយ ស្តីពី **ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅ**ឃុំសេដា ស្រុកលំផាត់ ខេត្តរតនៈគិរី** កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ **៥១**នាក់ (**៩%**ជាស្ត្រីជនជាតិទំពួន) ពីគ្រប់ភូមិក្នុងឃុំ ដែលរួមមាន តំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ សមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្នយកចិត្តទុកដាក់ដោះស្រាយ និង/ឬ គណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

### តម្រូវការជាអាទិភាពទាំង៥ ក្នុងឃុំសេដា ស្រុកលំផាត់ ខេត្តរតនៈគិរី

**១. ការដោះស្រាយបញ្ហាដីធ្លី**

- សូមឲ្យភាគីដែលពាក់ព័ន្ធជួយដោះស្រាយបញ្ហាដីធ្លី ដែលប៉ះពាល់ដល់ដីប្រជាពលរដ្ឋចំនួន ៩០ហិចតា ចំនួន២៥គ្រួសារ ក្នុងភូមិចំនួន៣ គឺភូមិឈាងហៃ ភូមិសមុត្រក្រោម និងភូមិថ្មី នៅចំនុចក្រងឈៀសតាស ដែលក្រុមហ៊ុនឌីអ៊ឹមគ្រុប ផ្ទេរដីនេះឲ្យក្រុមហ៊ុនតារ៉ៃ ជាក្រុមហ៊ុនឯកជនមួយដែលធ្វើការ ឈូសឆាយដំណាំស្វាយចន្ទី ខ្នុរ ថ្នាំជក់ សារម៉ាវ និងដីចំការវិលជុំមិនឲ្យប្រជាពលរដ្ឋទៅប្រកបមុខរបរចិញ្ចឹមជីវិតលើដីនោះឡើយ ហើយព្រមទាំងគំរាមកំហែងដោយយកកំលាំងកងរាជអាវុធហត្ថមកចាប់ប្រជាពលរដ្ឋបើហ៊ានចូលធ្វើចំការនៅតំបន់នេះ។ សូមដោះស្រាយឲ្យបាននៅឆ្នាំ២០១២នេះ។
- សុំផ្តល់ដីសម្បទានដល់ភូមិឈាងហៃចំនួន២គីឡូម៉ែត្របួនជ្រុង ដើម្បីពង្រីកភូមិ ដោយសារភូមិឈាងហៃបច្ចុប្បន្ននេះតូចហើយមានចំនួនប្រជាជនច្រើន។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។
- សូមជួយដោះស្រាយ និងអន្តរាគមន៍ទៅលើក្រុមហ៊ុនចំនួន២គឺ ទី១ក្រុមហ៊ុនសម្បទានហ្សុងវី ដែលបាញ់ថ្នាំតាមដើមឈើ កំណត់ព្រំប្រទល់យកដីចំការវិលជុំរបស់ប្រជាពលរដ្ឋនៅឃុំសេដា ចំនួន៤៨០ហិចតា ធ្វើឲ្យប៉ះពាល់ដល់៩៦គ្រួសារ និងទី២ក្រុមហ៊ុនអេឡេវចំនួន១០០ហិចតានៅភូមិសមុត្រលើស្ថិតក្នុងឃុំ



ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

សេដានេះ។ សូមដោះស្រាយឲ្យបាននៅឆ្នាំ២០១២នេះ។

**២. ការធ្វើផ្លូវ**

- សុំ**ធ្វើផ្លូវ**ចំនួន៥ខ្សែ ជាផ្លូវក្រាលគ្រួសក្រហមគឺៈ

+**ខ្សែទី១** មានប្រវែង៨គីឡូម៉ែត្រ ទទឹង៧ម៉ែត្រ ពីឃុំសេដា ទៅភូមិណាងហៃ និងដាក់លូចំនួន១២កន្លែង លូទី១អូរគោក ទី២អូរចាក់ ទី៣អូរតូច ទី៤អូរវាលស្រែ២កន្លែង ទី៥អូរកាលង ទី៦អូរវាលថ្មដា ទី៧អូរទ្រៀងចំនួន៣កន្លែង ទី៨អូរជាប់ស្ពានអូគ្រាវ ដោយលូទាំងអស់មានមុខកាត់១ម៉ែត្រ ប្រវែង៧ម៉ែត្រ និងធ្វើស្ពាន១កន្លែងនៅចំនុចអូរគ្រាវ មានប្រវែង១០ម៉ែត្រ ទទឹង៧ម៉ែត្រធ្វើពីបេតុង

+**ខ្សែទី២** មានប្រវែង៣គីឡូម៉ែត្រ ទទឹង៧ម៉ែត្រ ពីភូមិណាងហៃទៅភូមិជ្រៀក ឃុំលុងឃុង

+**ខ្សែទី៣** មានប្រវែង៣២គីឡូម៉ែត្រ ទទឹង៧ម៉ែត្រពីភូមិសមុត្រក្រោមទៅភូមិកែងសាន់ជាប់ដីខេត្តមណ្ឌលគិរី

+**ខ្សែទី៤** មានប្រវែង៣៣គីឡូម៉ែត្រ ទទឹង៧ម៉ែត្រ ពីភូមិសមុត្រក្រោមទៅទីរួមស្រុកលំផាត់

+**ខ្សែទី៥** មានប្រវែង៤គីឡូម៉ែត្រ ទទឹង៧ម៉ែត្រ ពីភូមិណាងហៃទៅតំបន់ទេសចរណ៍បឹងកាវ៉ាយក្នុងអោម។ សូមចាប់ផ្ដើមឆ្នាំ២០១២នេះតទៅ និងបញ្ចប់ឆ្នាំ២០១៣។

**៣. ការទប់ស្កាត់ការកាប់ព្រៃឈើ**

- សុំជួយទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ការរុករានយកដីព្រៃជាកម្មសិទ្ធិផ្ទាល់ខ្លួន និងតំបន់អភិរក្សរបស់សហគមន៍នៅឃុំសេដា ត្រង់ចំនុចព្រៃក្រុងស្រែតាស លើផ្ទៃដីចំនួន១៣០ហិចតាស្ថិតនៅភូមិណាងហៃ ពីក្រុមហ៊ុនឯកជនតាវ៉ែ។ សូមដោះស្រាយឲ្យបាននៅឆ្នាំ២០១២នេះ។

**៤. ការសាងសង់សាលាឃុំ និងសុំគ្រូបង្រៀនបន្ថែម**

- សុំសាងសង់សាលាឃុំ១ខ្នង ទៅតាមស្តង់ដារបស់ក្រសួងមហាផ្ទៃ នៅចំនុចឃុំសេដាលើដីរដ្ឋបាលបំរុងទុក ព្រោះបច្ចុប្បន្ននៅឃុំសេដានេះយកផ្ទះធ្វើជាសាលាឃុំ ធ្វើឲ្យប្រជាពលរដ្ឋពិបាកក្នុងការទំនាក់ទំនងការងារជាមួយក្រុមប្រឹក្សាឃុំ។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។
- សុំគ្រូបង្រៀនថ្នាក់បឋមសិក្សាចំនួន១៩នាក់ (ស្រី៥នាក់ និងប្រុស១៤នាក់) សម្រាប់បង្រៀននៅបឋមសិក្សាសេដាចំនួន៨នាក់ នៅបឋមសិក្សាណាងហៃ៦នាក់ និងនៅបឋមសិក្សាសមុត្រលើចំនួន៥នាក់។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។

**៥. ការធ្វើបង្គន់អនាម័យ អណ្តូងស្នប់ និងគ្រូពេទ្យ**

- សុំបង្គន់អនាម័យចំនួន១៥បង្គន់ ដោយបង្គន់នីមួយៗមានទទឹង២ម៉ែត្រx៣ម៉ែត្រ ធ្វើពីបេតុង ប្រក់ក្បឿងសម្រាប់ភូមិចំនួន៤ គឺភូមិណាងហៃចំនួន៤បង្គន់ ភូមិសមុត្រក្រោមចំនួន៤បង្គន់ ភូមិសមុត្រលើចំនួន៤បង្គន់ និងភូមិថ្មីចំនួន៣បង្គន់។ សូមឲ្យបាននៅឆ្នាំ២០១២។
- សុំអណ្តូងស្នប់ចំនួន៨ សម្រាប់ភូមិចំនួន៤ គឺភូមិណាងហៃចំនួន២អណ្តូង ភូមិសមុត្រលើចំនួន២អណ្តូង

ភូមិសមុត្រក្រោមចំនួន២អណ្តូង និងភូមិថ្មីចំនួន២អណ្តូង។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។
- សុំគ្រូពេទ្យប្រចាំការនៅប៉ុស្តិ៍សុខភាពឃុំសេដា ចំនួន៣នាក់ស្រី១ប្រុស២ និងមានថ្នាំគ្រប់គ្រាន់ដើម្បីព្យាបាល និងគ្រោះថ្នាក់ផ្សេងៗកើតឡើង។ សូមឲ្យបានឆ្នាំនៅឆ្នាំ២០១២នេះ។

មុនពេលបញ្ចប់សិក្ខាសាលាមានកម្មវិធីប្រគល់របាយការណ៍ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **ធំ ផាន់** តំណាងគណបក្សប្រជាជនបានមានប្រសាសន៍ថា «សូមឲ្យប្រជាពលរដ្ឋយើងទាំងអស់ដែលជាម្ចាស់ឆ្នោតកត់ត្រាទុកនូវអ្វីដែលយើងបានរកឃើញនៅពេលសិក្ខាសាលានេះ និងជម្រុញឲ្យមានការអភិវឌ្ឍន៍ទាំងអស់គ្នា ហើយប្រជាពលរដ្ឋយើងទាំងអស់គ្នាត្រូវទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំនៅពេលខាងមុខនេះកុំបីខាន»។

**សិក្ខាសាលានេះមានគោលបំណងឲ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖**

១. ការយល់ដឹងអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។
២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ-សង្កាត់របស់ខ្លួន។
៣. តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ ដាច់ស្រយាលនឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដានជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរុប (EU), OXFAM NOVIB, NPA និង Forum Syd

[1]**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

១-លោក **ម្លូខ មឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៨៧១ ៣២៦**

២-កញ្ញា **គោគ ស្រីពេជ្រ** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០៨៩ ៨១៨ ១៧៦**

[1] No. 076